# ការណែនាំអំពីការពិនិត្យមើលលទ្ធផលនៃការជ្រើសរើសសាលារៀន

សូមអានឯកសារនេះទាំងមូល មុនពេលធ្វើសកម្មភាពលើប្រព័ន្ធជ្រើសរើសសាលារៀន ដើម្បីធានាថា អ្នកយល់អំពីដំណើរការ។

<u>មាតិកា</u>


កាលបរិច្ឆេទសំខាន់ៗ 1
ការពិនិត្យមើលលទ្ធផល 2
ស្ថានភាពនៃការចាប់ឆ្នោត 3
យល់ដឹងពីជម្រើសទទួលយក និងបដិសេធ 4
ឆ្លើយតបនឹងសំណើក្នុងដំណាក់កាលសិស្សឆ្លើយតប 5
ផ្លាស់ប្តូរការជ្រើសរើសរបស់អ្នកក្នុងដំណាក់កាលសិស្សឆ្លើយតប 6
ព័ត៌មានសម្រាប់សិស្សក្នុងបញ្ជីរង់ចាំ 6
　ការតាមដានលេខរៀងក្នុងបញ្ជីរង់ចាំ 6
　ការឆ្លើយតបនឹងសំណើកៅអីពីបញ្ជីរង់ចាំ 7


## ***<u>កាលបរិច្ឆេទសំខាន់ៗ</u>***

| **ដំណាក់កាលសិស្សឆ្លើយតប** | |
|---|---|
| លទ្ធផលនៃដំណើរការចាប់ឆ្នោតជ្រើសរើសសាលារៀនត្រូវបានបង្ហាញជូន។ គ្រួសារអាចចូលក្នុងប្រព័ន្ធជ្រើសរើសសាលារៀន ដើម្បីពិនិត្យមើលលទ្ធផលចាប់ឆ្នោត។ | ក្រោយម៉ោង ៥ ល្ងាច នៅថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០២៤ |
| ថ្ងៃចុងក្រោយសម្រាប់ទទួលយកកន្លែងនៅសាលារៀន ដែលគេបានធ្វើសំណើជូនអ្នក។ | ឱ្យទាន់ម៉ោង ៥ ល្ងាច នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០២៤<br><br>**សំណើដែលមិនទាន់សម្រេចយក នឹងត្រូវបដិសេធចោលដោយស្វ័យប្រវត្តិនៅម៉ោង ៥ ល្ងាច ថ្ងៃសុក្រ ទី ២៦ ខែ មករា ឆ្នាំ ២០២៤។** |
| **ដំណាក់កាលបញ្ជីរង់ចាំ** | |
| *សំណើពីបញ្ជីរង់ចាំ នឹងត្រូវបានជូនដំណឹងប្រាប់ បន្ទាប់ពីចប់ដំណាក់កាលសិស្សឆ្លើយតប ហើយនឹងបន្តដំណើរការ។ នៅពេលគេធ្វើសំណើ អ្នកដាក់ពាក្យសុំមានពេល ៣ ថ្ងៃ ដើម្បីបញ្ជាក់ពីការទទួលយកនៅលើប្រព័ន្ធ។ ប្រព័ន្ធនឹងបដិសេធចោលដោយស្វ័យប្រវត្តិនូវសំណើពីបញ្ជីរង់ចាំណា ដែលមិនបានទទួលយក នៅមុនម៉ោង ៥ ល្ងាច នៅថ្ងៃទីបីនោះទេ។* | |

## ***ការពិនិត្យមើលលទ្ធផល***

1. ចូលទៅគេហទំព័រ [schoolselect.philasd.org](schoolselect.philasd.org) ហើយរកមើលបណ្តាញតភ្ជាប់ (links) ដែលនៅជិតផ្នែកខាងលើនៃទំព័រ។ មានប៊ូតុងចុចចូលដាច់ដោយឡែកសម្រាប់សិស្សរបស់ក្រសួងអប់រំ និងសិស្សក្រៅក្រសួងអប់រំ។ ចុចប៊ូតុង View Now (មើលឥឡូវនេះ) ដែលសមស្រប ដើម្បីចូលប្រើគណនីរបស់អ្នក។




2. បញ្ចូលព័ត៌មានរបស់អ្នក ដើម្បីចូលទៅក្នុងប្រព័ន្ធជ្រើសរើសសាលារៀន។ បន្ទាប់ពីចុចចូលរួច រកមើលផ្ទាំងឈ្មោះសិស្សរបស់លោកអ្នក។ ផ្ទាំងនោះនឹងបង្ហាញឈ្មោះសិស្ស ចំនួនលិខិតដាក់ពាក្យដែលបានដាក់ និងប៊ូតុង ***View All*** ។
    a. ចុចលើប៊ូតុង ***View All***។ រាល់លិខិតដាក់ពាក្យបច្ចុប្បន្នទាំងអស់សម្រាប់សិស្សនោះ នឹងត្រូវបង្ហាញលើផ្ទាំងអេក្រង់ ជាមួយនឹងស្ថានភាពនៃលិខិតដាក់ពាក្យដែលត្រូវគ្នានៅ កម្មវិធី/សាលារៀន នីមួយៗ។



## ***ស្ថានភាពនៃការចាប់ឆ្នោត***

លិខិតដាក់ពាក្យអាចមានស្ថានភាពមួយ ក្នុងចំណោមស្ថានភាពបី ដូចខាងក្រោមនេះ ដែលជាលទ្ធផលនៃការចាប់ឆ្នោតជ្រើសរើសសាលារៀន។ សិស្សដែលបានដាក់ពាក្យសុំទៅសាលារៀនច្រើនកន្លែង អាចមានស្ថានភាពផ្សេងៗសម្រាប់លិខិតដាក់ពាក្យសុំរបស់ខ្លួន។

- **Offered (បានធ្វើសំណើ)**- ប្រសិនបើអ្នកមានលក្ខណៈសម្បត្តិសម្រាប់ការចាប់ឆ្នោត ហើយមានសំណើផ្តល់កន្លែងនោះ អ្នកនឹងមើលឃើញពាក្យ *Offered*។ នៅជិតពាក្យ *Offered* អ្នកនឹងមើលឃើញសេចក្តីបញ្ជាក់អំពីកាលបរិច្ឆេទ និងពេលវេលា ដែលសំណើផ្តល់កន្លែងនេះនឹងអស់សុពលភាព។ អ្នកក៏នឹងមើលឃើញប៊ូតុងពីរផងដែរ គឺប៊ូតុងក្រហម ***Decline*** និងប៊ូតុងបៃតង ***Accept*** ក្រោមឈ្មោះ កម្មវិធី/សាលារៀន នោះ។
- **Ineligible** (មិនមានសិទ្ធិ) **- បេក្ខជនមិនត្រូវតាមលក្ខណៈវិនិច្ឆ័យមួយ ឬច្រើនជាង-** ប្រសិនបើអ្នកមិនមានសិទ្ធិទទួលការចាប់ឆ្នោតទេ អ្នកនឹងឃើញពាក្យថា **Ineligible** (មិនមានសិទ្ធិ) - *បេក្ខជនមិនត្រូវតាមលក្ខខណ្ឌមួយ ឬច្រើនជាង* នៅក្រោម ឈ្មោះសាលា/កម្មវិធី នោះ។
- **Waitlisted (# X) (ក្នុងបញ្ជីរង់ចាំ (# X))** - ប្រសិនបើអ្នកមានលក្ខណៈសម្បត្តិសម្រាប់ការចាប់ឆ្នោត ប៉ុន្តែគ្មានសំណើផ្តល់កន្លែងទេ អ្នកនឹងមើលឃើញពាក្យ *Waitlisted* និង (# X) ដោយលេខរៀងពិតប្រាកដរបស់សិស្សនៅក្នុងបញ្ជីរង់ចាំនឹងត្រូវបង្ហាញជាពណ៌ទឹកក្រូច។



## ***ការយល់ដឹងពីជម្រើសទទួលយក និងបដិសេធ***

លិខិតដាក់ពាក្យសុំមានស្ថានភាព *Offered* និងមានប៊ូតុង ***Decline (បដិសេធ)*** និងប៊ូតុង ***Accept (ទទួលយក)***។

ការចុចប៊ូតុង ***Accept*** នឹងបញ្ជាក់ពីការទទួលយកនូវសំណើផ្តល់កន្លែង។ ការចុចប៊ូតុង ***Decline*** នឹងលុប កម្មវិធី/សាលា រៀន នោះជាអចិន្ត្រៃយ៍ចេញពីលិខិតដាក់ពាក្យសុំចាប់ឆ្នោតរបស់អ្នក។ **កុំចុចប៊ូតុង “DECLINE” លើកលែងតែអ្នកប្រាកដថា អ្នកមិនចង់រៀននៅសាលារៀននោះ។** កុំចុចប៊ូតុង “Decline” ប្រសិនបើអ្នកគិតថា អ្នកអាចប្តូរចិត្តមុនថ្ងៃកំណត់ឆ្លើយតប សំណើ នៅថ្ងៃសុក្រ ទី ២៦ ខែ មករា ឆ្នាំ ២០២៤ គឺមុនម៉ោង ៥ ល្ងាច។ ប្រព័ន្ធនឹងបដិសេធចោលដោយស្វ័យប្រវត្តិនូវសំណើ ដែលមិនបានទទួលយក នៅមុនម៉ោង ៥ ល្ងាច នៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២៤។




- **ក្នុងដំណាក់កាលសិស្សឆ្លើយតប (ថ្ងៃសុក្រ ទី ១៩ ខែ មករា នៅម៉ោង ៥ ល្ងាច ដល់ថ្ងៃសុក្រ ទី ២៦ ខែ មករា មុនម៉ោង ៥ ល្ងាច)** សិស្សនឹងមានលទ្ធភាពផ្លាស់ប្តូរសាលារៀនដែលខ្លួនកំពុងជ្រើសរើសបានច្រើនដង ដែលខ្លួនចង់បាន ដោយ ចុចប៊ូតុង Accept សម្រាប់លិខិតដាក់ពាក្យសុំកន្លែងក្នុងកម្មវិធី ឬសាលារៀន។ **ការចុចប៊ូតុង *Decline* នឹងលុបសាលា រៀន ឬកម្មវិធីជាអចិន្ត្រៃយ៍ចេញពីជម្រើសរបស់អ្នក ហើយប្រសិនបើសំណើ កម្មវិធី/សា លារៀន ត្រូវបានបដិសេធចោល កម្មវិធី/សាលារៀន នោះនឹងលែងមានទៀតហើយសម្រាប់ការជ្រើសរើស។**
  - **កំណត់សំគាល់៖** ឱកាសចុចទទួលយក ត្រូវបិទនៅម៉ោង ៥ ល្ងាច ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២៤ សាលារៀនចុងក្រោយ ដែលអ្នកបានចុចប៊ូតុង ACCEPT នឹងត្រូវកត់ត្រាជាសាលារៀនដែលបានជ្រើសរើសសម្រាប់ សិស្ស។ រាល់សំណើសាលារៀនផ្សេងទៀតនឹងត្រូវលុបចោលដោយស្វ័យប្រវត្តិចេញពីប្រព័ន្ធ។ លិខិតដាក់ ពាក្យសុំមានស្ថានភាព *Waitlisted* នឹងរក្សានៅដដែល។
- **ក្នុងដំណាក់កាលបញ្ជីរង់ចាំ (សំណើពីបញ្ជីរង់ចាំនឹងត្រូវបានចែករំលែក បន្ទាប់ពីចប់ដំណាក់កាលសិស្សឆ្លើយតប ហើយ នឹងដំណើរការជាបន្ត។)** សិស្សនឹងមានលទ្ធភាព**ទទួលយកសំណើពីបញ្ជីរង់ចាំតែមួយ**គត់។ ប្រសិនបើគេសម្រេចទទួល យកនូវសំណើដែលផ្តល់ជូន ក្រោយពីបានប្តូរពីស្ថានភាព *Waitlist* ទៅស្ថានភាព *Offered* ប្រព័ន្ធនឹងបដិសេធ ចោលដោយស្វ័យប្រវត្តិនូវសំណើមុនៗដែលបានទទួលយក ហើយសិស្សនឹងត្រូវលុបចេញពីបញ្ជីរង់ចាំផ្សេងទៀត

យើងសូមលើកទឹកចិត្តយ៉ាងខ្លាំងចំពោះអ្នកដាក់ពាក្យសុំ ដែលបានទទួលសំណើផ្តល់កន្លែង ឲ្យទទួលយកកន្លែងនោះ នៅមុនថ្ងៃ កំណត់ នៅម៉ោង ៥ ល្ងាច ថ្ងៃសុក្រ ទី ២៦ ខែ មករា ឆ្នាំ ២០២៤។ សំណើណា ដែលមិនបានទទួលយក នឹងត្រូវបដិ សេធចោល ដោយស្វ័យប្រវត្តិនៅលើប្រព័ន្ធ នៅថ្ងៃសុក្រ ទី ២៦ ខែ មករា នៅម៉ោង ៥ ល្ងាច។ ការទទួលយកសំណើក្នុងដំណាក់កាលសិស្ស ឆ្លើយតប នឹងមិនប៉ះពាល់ដល់លិខិតដាក់ពាក្យសុំណាមួយក្នុងបញ្ជីរង់ចាំឡើយ។ សំណើពីបញ្ជីរង់ចាំនឹងត្រូវជូនដំណឹងប្រាប់ ក្រោយពីចប់ដំណាក់កាលសិស្សឆ្លើយតប ហើយសំណើពីបញ្ជីរង់ចាំនឹងបន្តដំណើរការ។

អ្នកដាក់ពាក្យសុំ ដែលមិនទទួលយកសំណើក្នុងដំណាក់កាលសិស្សឆ្លើយតប ឬដំណាក់កាលបញ្ជីរង់ចាំ នឹងបន្តមានលក្ខ ណៈសម្បត្តិរៀននៅសាលារៀនក្នុងតំបន់របស់ខ្លួន សម្រាប់ឆ្នាំសិក្សា ២០២៤-២០២៥។

# ***ឆ្លើយតបនឹងសំណើក្នុងដំណាក់កាលសិស្សឆ្លើយតប***

1. ចុចចូលទៅក្នុងប្រព័ន្ធជ្រើសរើសសាលារៀន ហើយស្វែងរកផ្ទាំងឈ្មោះសិស្សរបស់អ្នក។ ចុចប៊ូតុង ***View All*** ដើម្បីបង្ហាញលិខិតដាក់ពាក្យសុំបច្ចុប្បន្ន ជាមួយនឹងស្ថានភាពនៃពាក្យសុំកន្លែងនៅ សាលារៀន/កម្មវិធី នីមួយៗ។




2. ពិនិត្យមើលស្ថានភាពនៃពាក្យសុំនីមួយៗ។ ដើម្បីទទួលយក*សំណើ* ត្រូវស្វែងរកពាក្យសុំ និងចុចប៊ូតុង ***Accept*** ។




3. បន្ទាប់ពីចុចប៊ូតុង ***Accept*** ផ្ទាំងបញ្ជាក់នឹងលេចឡើង។ ដើម្បីបញ្ជាក់ពីការទទួលយកសំណើនេះ ចុចប៊ូតុងបៃតង ***Yes, Accept Placement*** ។
    a. ប្រសិនបើអ្នកមិនទាន់ទទួលយកសំណើនេះនៅពេលនេះទេ ចុចប៊ូតុង ***Cancel*** ដើម្បីបិទផ្ទាំងបញ្ជាក់ដែលលេចឡើងនោះ ហើយត្រឡប់ទៅផ្ទាំងអេក្រង់ពាក្យសុំចាប់ឆ្នោតវិញ។




4. បន្ទាប់ពីបញ្ជាក់ទទួលយកសំណើរួច ស្ថានភាពចាប់ឆ្នោតនឹងប្តូរពី *Offered* ទៅ *Offer Accepted* ។



## *ផ្លាស់ប្តូរការជ្រើសរើសរបស់អ្នកក្នុងដំណាក់កាលសិស្សឆ្លើយតប*

ប្រសិនបើអ្នកដាក់ពាក្យសុំទទួលយកនូវសំណើផ្តល់កន្លែងក្នុងដំណាក់កាលសិស្សឆ្លើយតប រាល់សំណើផ្តល់កន្លែងផ្សេងទៀតដែលមានស្រាប់ នឹងនៅមានដដែល ហើយសំណើទាំងនេះនឹងបន្តលេចឡើងជាមួយប៊ូតុង ***Decline*** ឬ ***Accept*** ។

- ប្រសិនបើអ្នកដាក់ពាក្យសុំចង់ផ្លាស់ប្តូរការជ្រើសរើសរបស់ខ្លួន ពួកគេអាចចុចប៊ូតុង ***Accept*** ចំពោះសំណើមួយក្នុងចំណោមសំណើផ្តល់កន្លែងផ្សេងទៀតរបស់ខ្លួន។
- ប្រព័ន្ធនឹងធ្វើបច្ចុប្បន្នភាពលើការជ្រើសរើសថ្មីបំផុតរបស់ពួកគេ ដើម្បីបង្ហាញស្ថានភាព *Offer Accepted* ហើយសំណើមុនណាដែលបានទទួលយក នឹងត្រូវប្តូរ ដោយបង្ហាញជម្រើស ***Decline*** និង ***Accept*** វិញ។

## *ព័ត៌មានសម្រាប់សិស្សក្នុងបញ្ជីរង់ចាំ*

**ស្ថានភាពក្នុងបញ្ជីរង់ចាំមិនធានាថា នឹងមានសំណើផ្តល់កន្លែងឡើយ។** សំណើពីបញ្ជីរង់ចាំ នឹងត្រូវជូនដំណឹងប្រាប់ បន្ទាប់ពីចប់ដំណាក់កាលសិស្សឆ្លើយតប ហើយនឹងបន្តដំណើរការ។ សំណើពីបញ្ជីរង់ចាំណា ដែលបានធ្វើហើយនឹងមានសុពលភាពសម្រាប់រយៈពេល ៣ ថ្ងៃ ប្រតិទិន គិតចាប់ពី ថ្ងៃ/ម៉ោង ធ្វើសំណើនោះ នៅមុនពេលសំណើពីបញ្ជីរង់ចាំនោះផុតសុពលភាព។

### ការតាមដានលេខរៀងក្នុងបញ្ជីរង់ចាំ

សិស្សអាចតាមដានលេខរៀងក្នុងបញ្ជីរង់ចាំរបស់ខ្លួន ដោយចូលទៅក្នុងប្រព័ន្ធជ្រើសរើសសាលារៀន ហើយមើលផ្ទាំងពាក្យសុំចាប់ឆ្នោត។ សំណើពីបញ្ជីរង់ចាំអាចធ្វើឡើងនៅពេលមានកន្លែងទំនេរ។

- សិស្ស និងក្រុមគ្រួសារនឹងមិនទទួលបានការជូនដំណឹងឡើយ ប្រសិនបើពាក្យសុំរបស់គេបានប្តូរទៅលេខផ្សេងនៅក្នុងបញ្ជីរង់ចាំ។
- សិស្ស និងក្រុមគ្រួសារនឹងទទួលបានការជូនដំណឹង ប្រសិនបើពាក្យសុំរបស់ខ្លួនប្តូរពីបញ្ជីរង់ចាំទៅបញ្ជី offered សម្រាប់ សាលារៀន/កម្មវិធី។ បន្ថែមលើការជូនដំណឹងនោះ ពាក្យសុំរបស់គេនឹងប្តូរពីស្ថានភាព Waitlisted (# X) ទៅស្ថានភាព Offered។

<u>ការឆ្លើយតបនឹងសំណើផ្តល់កន្លែងពីបញ្ជីរង់ចាំ</u>

ពាក្យសុំដែលប្តូរពីស្ថានភាព *Waitlisted* ទៅស្ថានភាព *Offered* មិនត្រូវបានចាត់ទុកថា ជាការទទួលយកកន្លែងទេ លើកលែងតែការទទួលយកត្រូវបានសម្រេចចុងក្រោយនៅលើប្រព័ន្ធ។ អ្នកដាក់ពាក្យសុំនឹងមានពេល ៣ ថ្ងៃ ប្រតិទិន គិតចាប់ពី ថ្ងៃ/ម៉ោង ធ្វើសំណើ ដើម្បីទទួលយកសំណើពីបញ្ជីរង់ចាំនោះ។ **អ្នកដាក់ពាក្យសុំអាចទទួលយកសំណើផ្តល់កន្លែងបានតែមួយគត់ ក្នុងអំឡុងរយៈពេលរង់ចាំ។ ប្រសិនបើមានសំណើផ្តល់កន្លែង ហើយសំណើនោះត្រូវបានទទួលយកក្នុងដំណាក់កាលនេះ រាល់ការបញ្ជាក់ទទួលយកមុនៗទាំងអស់ និងបញ្ជីរង់ចាំផ្សេងទៀតនឹងត្រូវបដិសេធចោលដោយស្វ័យប្រវត្តិ។**

1. ក្រោយពីទទួលការជូនដំណឹងថា កូនរបស់អ្នកត្រូវបានឯកភាពសម្រាប់សាលារៀនដែលពួកគេស្ថិតនៅក្នុងបញ្ជីរង់ចាំពីមុន សូមចូលទៅក្នុងប្រព័ន្ធជ្រើសរើសសាលារៀន។ ស្វែងរកផ្ទាំងឈ្មោះសិស្សរបស់អ្នក។ ចុចប៊ូតុង ***View All*** ។




2. ពិនិត្យមើលលិខិតដាក់ពាក្យសុំរបស់អ្នក។
    a. លិខិតដាក់ពាក្យសុំណា ដែលមានសំណើផ្តល់កន្លែង ដែលមិនបានទទួលយក ក្នុងដំណាក់កាលសិស្សឆ្លើយតប នឹងមានក្នុងស្ថានភាព *Declined*។
    b. លិខិតដាក់ពាក្យសុំណា ដែលមានសំណើផ្តល់កន្លែង ដែលបានទទួលយក ក្នុងដំណាក់កាលសិស្សឆ្លើយតប នឹងមានក្នុងស្ថានភាព *Offer Accepted* ។
    c. លិខិតដាក់ពាក្យសុំណា ដែលប្តូរពីស្ថានភាព Waitlist ទៅ Offered ក្នុងដំណាក់កាលបញ្ជីរង់ចាំ នឹងមានក្នុងស្ថានភាព *Offered* ។



3. លិខិតដាក់ពាក្យសុំ ដែលមានស្ថានភាព *Offered* ក្នុងដំណាក់កាលបញ្ជីរង់ចាំ នឹងមានបញ្ចូលនូវសេចក្តីលម្អិតអំពីពេលវេលាដែលសំណើនោះត្រូវផុតសុពលភាព។ ថ្ងៃ និងម៉ោងក្នុងសេចក្តីលម្អិតទាំងនោះ នឹងអាស្រ័យលើពេលវេលាធ្វើសំណើដំបូង ហើយនឹងមាន**ពេលបីថ្ងៃប្រតិទិន គិតចាប់ពីថ្ងៃធ្វើសំណើដំបូង**។ *ត្រូវយកចិត្តទុកដាក់លើថ្ងៃ និងម៉ោងនេះ។ ប្រសិនបើអ្នកចង់ទទួលយកសំណើពីបញ្ជីរង់ចាំនេះ អ្នកត្រូវតែទទួលយកសំណើនេះ នៅមុនពេលសំណើផុតសុពលភាព។*




4. ដើម្បីទទួលយកសំណើផ្តល់កន្លែង ចុចប៊ូតុង ***Accept***។ ប្រសិនបើអ្នកមិនចង់ទទួលយកសំណើពីបញ្ជីរង់ចាំទេ អ្នកអាចអត់ធ្វើសកម្មភាពអ្វីក៏បាន ហើយសំណើនោះនឹងត្រូវបដិសេធចោលដោយស្វ័យប្រវត្តិនៅថ្ងៃ/ម៉ោងផុតកំណត់។




ត្រូវចាំថា ប្រសិនបើអ្នកទទួលយកសំណើផ្តល់កន្លែងពីបញ្ជីរង់ចាំ ប្រព័ន្ធនឹងបដិសេធចោលដោយស្វ័យប្រវត្តិនូវរាល់ការទទួលយកមុនៗ **ហើយ**នឹងបដិសេធចោលដោយស្វ័យប្រវត្តិនូវរាល់ស្ថានភាពបញ្ជីរង់ចាំផ្សេងទៀត។ <u>អ្នកអាចទទួលយកសំណើពីបញ្ជីរង់ចាំបានតែមួយគត់។</u>